# វិយោគកថា

សូមក្រាបថ្វាយបង្គំព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រមទាំងព្រះធម៌និងព្រះសង្ឃជាទីគោរពសក្ការៈ។ សូមគារវៈព្រះថេរានុថេរៈគ្រប់ព្រះអង្គ។ សូមចំរើនពរញាតិញោមពុទ្ធបរិស័ទ ក្រុមគ្រួសារសពនិងភ្ញៀវកិត្តយស ទាំងអស់ដែលមានវត្តមាននៅទីនេះ ជាទីមេត្រី។

ព្រះតេជគុណជាទីសក្ការៈ ញាតិញោមទាំងអស់ជាមេត្រី ទិវានេះគឺជាទិវាមួយដែលយើងទាំងអស់គ្នាពោរពេញទៅដោយសេចក្តីរន្ធត់តក់ស្លុតដែលមិននឹកស្មានដល់។ យើងបានមកជួបជុំគ្នាក្នុងទីនេះ សុទ្ធសឹងតែពាំនាំនូវសេចក្តីទុក្ខក្រៀមក្រំ។ យើងទាំងអស់ពិតជាយល់និងដឹងច្បាស់ដោយខ្លួនឯង លើកលែងតែអ្នកស្រីមហាឧបាសិកា**ហាន់ លី** ម្នាក់ប៉ុណ្ណោះ ដែលយើងមិនដឹងថា តើមហាឧបាសិកាទទួលដឹងនូវភាពក្រៀមក្រំរបស់យើងទាំងអស់គ្នាយ៉ាងណានោះទេ?

អ្នកស្រីមហាឧបាសិកាពោរពេញទៅដោយកុសលធម៌ ទន់ភ្លន់គ្រប់ឥរិយាបទទាំងអស់នោះកំពុងតែសម្រានយ៉ាងស្ងប់ស្ងាត់នៅចំពោះមុខយើងទាំងអស់គ្នា។ តើឧបាសិកាដឹងទេថា យើងទាំងអស់គ្នាមកជួបជុំគ្នានៅទីនេះ ទាមទារឱ្យអ្នកស្រីកុំទៅចោលយើងទាំងអស់គ្នា យើងទាំងអស់គ្នាមិនចង់ឱ្យលោកឈានជើង ឬ ហោះហើរទៅណាចាកចេញពីយើងទាំងអស់គ្នាទេ តែធ្វើម្តេចបានបើព្រះសម្មាសម្ពុទ្ធប្រៀបធៀបមនុស្សយើងទៅនឹងឆ្នាំងដី ដែលជាងឆ្នាំងបានធ្វើហើយ តែងតែនឹងបែកប្រេះធ្លាយទៅវិញជាធម្មតាយ៉ាងណាអ្នកស្រីក៏គង់តែនឹងបែកចេញពីយើងទាំងអស់គ្នាដែរ។ តែអ្វីដែលយើងក្រៀមក្រំនោះ ស្វាមី កូនៗ ចៅៗ ព្រមទាំងញាតិមិត្តពុទ្ធបរិស័ទទាំងអស់នឹងគ្មានឱកាសបានឃើញព្រះភ័ក្ត្រ អាកប្បកិរិយាទន់ភ្លន់ និងពាក្យសំដីនិយាយសាសងផ្តោះផ្តងមេត្រី របស់អ្នកស្រីទៀតទេ។

ព្រះមហាថេរៈជាទីគារវៈ ញាតិញោមពុទ្ធបរិស័ទនិងក្រុមគ្រួសារសពជាទីមេត្រី អាត្មាភាពសោកស្តាយមហាឧបាសិកា**ហាន់ លី** ណាស់។ អាត្មាធ្លាប់បានជួបឧបាសិកាច្រើនដងដែរ ឧបាសិកាមានសទ្ធាមុតមាំក្នុងព្រះពុទ្ធសាសនា ហើយមានមេត្តាសប្បុរសធម៌ខ្លាំងណាស់។ មហាឧបាសិកាជាភរិយាដ៏ល្អ ជាមាតាដ៏ល្អ ជាយាយដ៏ល្អ ជាញាតិជិតខាងដ៏ល្អ និងជាសមាជិកសង្គមដ៏ល្អ។ យើងឃើញហើយថាក្រៅអំពីទំនួលខុសត្រូវទទួលបន្ទុកជាមេគ្រួសារដ៏ល្អ ឧបាសិកាជាអ្នកចូលរួមយ៉ាងសកម្មក្នុងសង្គមថែមទៀតផង។ ការយកចិត្តទុកដាក់ចំពោះកូនចៅរបស់មហាឧបាសិកាជាហេតុការណ៍ដែលមិនអាចបំភ្លេចបាន។ ដូចដែលយើងដឹងអ្នកស្រីខ្វល់ខ្វាយរៀបចំរៀបមង្គលការឱ្យបុត្រីជាទីស្រឡាញ់ តែហេតុការណ៍កើតឡើងយ៉ាងទាន់ហន់ យើងមិនអាចដឹងទុកជាមុនថា ពិធីរៀបមង្គលការក្លាយទៅជាពិធីធ្វើបុណ្យខ្មោចទៅវិញ។ នេះជាហេតុការណ៍ពិតដែលបញ្ជាក់នូវអនិច្ចំ ទុក្ខំ និងអនត្តា អ្វីគ្រប់យ៉ាងគឺមិនទៀតទាត់ អ្វីគ្រប់យ៉ាងគឺជាទុក្ខ អ្វីគ្រប់យ៉ាងគឺមិនមែនជារបស់ខ្លួន។ តែទោះជាយ៉ាងណាក៏ដោយ យើងសង្កេតឃើញលោកយាយមហា

ឧបាសិកាផ្ចិតផ្ចង់តំរង់ស្មារតីខ្លាំងណាស់ចំពោះកូនចៅ មានទំនួលខុសត្រូវរហូតដល់ដង្ហើមចុងក្រោយរបស់ខ្លួន។ មហាឧបាសិកាគ្មានភាពញាប់ញ័រក្នុង ការទទួលខុសត្រូវក្នុងភាពជាម្តាយឬជាយាយដ៏ល្អរបស់កូនៗនិងចៅៗឡើយ។ ភាពរឹងប៉ឹងនិងកុសលធម៌ ការទំនួលខុសត្រូវខ្ពស់ និងការមានសទ្ធាមុតមាំក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ របស់ឧបាសិកាធ្វើឱ្យយើងចងចាំនិងអួលណែនឱរាពេលនឹកឃើញនិងសំលឹងឃើញរូបកាយឧបាសិកាដេកនៅស្តូកស្តឹងឥតមានកំរើក នៅទីនេះ។ តែធ្វើម្តេចទៅ ទោះបីស្តេចចក្រពត្តិ ឬវត្ថុសក្តិសិទ្ធិដែលយើងតែងជឿថាមានបុណ្យបារមីខ្លាំងប៉ុណ្ណា ក៏មិនអាចបញ្ចៀសឧបាសិកាកុំឱ្យស្លាប់ឬជប់ឧបាសិកាឱ្យរស់រានមានជីវិតឡើងវិញបានឡើយ។ ដូចដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា “ ទោះអ្នកជាមនុស្សសាមញ្ញ អ្នកសុំទានគេឬមហាសេដ្ឋី ល្ងង់ឬឆ្លាត ខ្ពស់ឬទាប អាក្រក់ឬស្អាត ព្រះព្រហ្មឬយក្សអសុរី សុទ្ធតែស្ថិតក្រោមច្បាប់នៃអនិច្ចំ ទុក្ខំ និងអនត្តាទាំងអស់” ។

អនិច្ចំឈ្មោះថាមិនទៀង កើតហើយល្អៀងស្លាប់ទៅវិញ
ទុក្ខំតែងទោម្នេញ អោយលោកអ្នកស្រក់ទឹកភ្នែក
អនត្តាមិនមែនខ្លួន កូនមាសស្ងួនមិនអាចជ្រៀតជ្រែក
កើតចាស់ឈឺស្លាប់ ជាច្បាប់ពិតលើលោកា ។

ព្រះសម្មាសម្ពុទ្ធសំដែងថា “ ធម៌ណាដែលមានឈ្មោះអនិច្ចតាធម៌ គឺសភាពប្រែប្រួលមិនទៀងទាត់ អនិច្ចតាធម៌នេះ មិនមែនជាធម៌សំរាប់អ្នកស្រុកតែមួយៗទេ មិនមែនជាធម៌សំរាប់អ្នកនិគមតែមួយៗទេ ឬនឹងថាជាធម៌សំរាប់ត្រកូលតែមួយៗក៏មិនមែនទេ។ អនិច្ចតាធម៌នេះ ជាធម៌សម្រាប់មនុស្សសត្វ ព្រមទាំងទេវតា មារព្រហ្មទាំងអស់គ្រប់រូប” ។ “ ធម៌ណាដែលមានឈ្មោះទុក្ខតាធម៌ គឺសភាពជាទុក្ខ ទុក្ខតាធម៌នេះ មិនមែនជាធម៌សំរាប់អ្នកស្រុកតែមួយៗទេ មិនមែនជាធម៌សំរាប់អ្នកនិគមតែមួយៗទេ ឬនឹងថាជាធម៌សំរាប់ត្រកូលតែមួយៗក៏មិនមែនទេ។ ទុក្ខតាធម៌នេះ ជាធម៌សម្រាប់មនុស្សសត្វ ព្រមទាំងទេវតា មារព្រហ្មទាំងអស់គ្រប់រូប” ។ “ ធម៌ណាដែលមានឈ្មោះអនត្តាធម៌ គឺសភាពមិនមែនជារបស់ខ្លួន អនត្តាធម៌នេះ មិនមែនជាធម៌សំរាប់អ្នកស្រុកតែមួយៗទេ មិនមែនជាធម៌សំរាប់អ្នកនិគមតែមួយៗទេ ឬនឹងថាជាធម៌សំរាប់ត្រកូលតែមួយៗក៏មិនមែនទេ។ អនត្តាធម៌នេះ ជាធម៌សម្រាប់មនុស្សសត្វ ព្រមទាំងទេវតាមារព្រហ្មទាំងអស់គ្រប់រូប” ។

ខណះនេះយើងឃើញយ៉ាងប្រត្យក្សថា មហាឧបាសិកា**ហាន់ លី** កំពុងដេកស្តូកស្តឹង ស្ងប់ស្ងាត់ហាក់ដូចជាមិនអើពើនឹងពាក្យសំដីអង្វរករនិងទុក្ខក្រៀមក្រំរបស់យើងទាំងអស់គ្នាសោះ។ នេះជាសភាពពិតនៃជីវិត ដែលប្រកបដោយសង្ខារធម៌ទាំងឡាយប្រាំ មានរូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ។ ពេលនេះវេទនា សញ្ញា សង្ខារ និងវិញ្ញាណ របស់ឧបាសិកាបានឃ្លាតឆ្ងាយទៅអស់ហើយ

សល់នៅតែរូបធាតុ ដែលយើងមើលឃើញសុទ្ធតែផ្សំឡើងដោយធាតុទឹក ធាតុដី ធាតុភ្លើង និងធាតុខ្យល់ ហើយនៅមិនយូរប៉ុន្មាន ធាតុទាំងបួននេះនឹងរត់ទៅរកធាតុដើមរបស់គេវិញទាំងអស់ ។

ព្រះមហាថេរៈ ញាតិញោមពុទ្ធបរិស័ទ និងក្រុមគ្រួសារសព មនុស្សយើងទាំងអស់គ្នាមិនខុសពីលោកមហាឧសិកាទេ បើខុសក៏ខុសត្រង់ឧបាសិកាបានបំពេញតួនាទីជាម្តាយ ជាជីដូន ឬភរិយាបានល្អជាងយើង ហើយមានអាយុរហូតដល់៥៨ឆ្នាំ ទើបធ្វើមរណកាលទៅ តែអ្វីដែលដូចគ្នានោះគឺពេលយើងស្លាប់ទៅ យើងមិនអាចយកអ្វីទៅជាមួយបានឡើយ។ កូនជាទីស្រលាញ់ ចៅជាទីស្រលាញ់ ឬមាសពេជ្រកែវកងច្រើនយ៉ាងណាក៏ដោយ នឹងនៅសល់ ក្លាយជារបស់អសាបង់ឥតន័យឥតខ្លឹមសារ។ ប៉ុន្តែអ្វីដែលឧបាសិកាអាចយកទៅបាននៅពេលនេះ គឺមានតែអំពើជាបុណ្យជាកុសល និងគុណធម៌ដែលមហាឧបាសិកាបានសន្សំក្នុងរយះពេលកន្លងមក។ ដូចយើងដឹងស្រាប់ហើយថាលោកយាយធ្លាប់បាន ធ្វើបុណ្យ និមន្តព្រះសង្ឃឆាន់ ជឿទៅលើកម្មថាធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ព្រមទាំងជឿទៅលើគុណព្រះរតនត្រ័យ។ ហើយក្នុងឆាកជីវិតរបស់ឧបាសិកា ប្រកបមុខរបរចិញ្ចឹមជីវិតតាមសម្មាអាជីវៈ ចិញ្ចឹមកូនចៅទាំងអស់ដោយទំនួលខុសត្រូវ និងទទួលភារៈជួយដល់អ្នកដទៃនិងសង្គមថែមទៀតផង ។

សេចក្តីស្លាប់គឺទៀងទាត់ តែជីវិតរបស់យើងម្នាក់ៗ គឺមិនទៀងទាត់ទេ ដូច្នេះមានតែខំកសាងអំពើល្អដូចដែលមានមហាឧបាសិកា**ហាន់ លី** ជាគំរូស្រាប់។

ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា “ **រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ** ដែលប្រែជាន័យសេចក្តីបានថា *រូបកាយរលត់រលាយទៅ កេរ្តិ៍ឈ្មោះនៅឥតរសាយ ល្អនិងអាក្រក់ឮវែងឆ្ងាយ គួរស្តាយខំសាងអំពើល្អ*” ។

ហើយម្យ៉ាងវិញទៀត កូនដែលជាមាសស្ងួនរបស់ម្តាយ គួរតែចិញ្ចឹមមើលការខុសត្រូវ ទំនុកបំរុងមាតាបិតាពេលដែលគាត់ចាស់ជរាទៅ ជាពិសេសកូនចៅត្រូវតែថែទាំមាតាបិតា ចិញ្ចឹមបីបាច់ និងធ្វើបុណ្យឱ្យគាត់ឱ្យបានច្រើន នៅពេលដែលនៅមានជីវិតនៅឡើយ។ កូនចៅទាំងអស់ត្រូវតែដឹងឱ្យច្បាស់ថាមាតាបិតាគឺជាព្រះពិតរបស់យើងទាំងឡាយ ហើយយើងគួរតែទំនុកបំរុងនិងធ្វើបុណ្យឱ្យគាត់នៅពេលដែលគាត់នៅមានជីវិតនៅឡើយ ដូចដែល**បណ្ឌិតអ៊ូ ចុង** ដែលជាអ្នកតែងកំណាព្យដ៏ល្បីល្បាយម្នាក់របស់ខ្មែរបានពោលថា

ព្រះពុទ្ធដាក់ឈ្មោះ

បាលីពីរោះ បុព្វទេវា “ ទេវតាខាងដើម”

អ្នកផ្តើមរក្សា បុត្រីបុត្រា ហៅទេវតាផ្ទះ ។

| | | |
|---|---|---|
| | គឺម្តាយ ឪពុក | |
| ជាអ្នកម្ចាស់ស្រុក | កូនមិនសំពះ | ម៉ែឪទូន្មាន |
| ឈ្លានពានចង់ឈ្នះ | សត្រូវនឹងព្រះ | កន្ទ្រោងអាត្មា ។ |
| | ប្រទូសរ៉ាយ | |
| នឹងឪពុកម្តាយ | ស្រែកហៅទេវតា | អំពីខាងក្រៅ |
| ដឹងនៅឯណា | ឈ្មោះនឹងទេវតា | គឺម៉ែឪឯង ។ |
| | តែងតែលំបាក | |
| ក្រីក្រតោកយ៉ាក | ជាតិនេះឃើញស្តែង | ហើយទៅវងទុក្ខ |
| ខាងមុខពុំលែង | លុះភ័យទើបស្វែង | រកហោរគ្រូទាយ ។ |

---

ម្យ៉ាងទៀតរឿងធ្វើបុណ្យបុត្រាបុត្រីគួរយល់ឱ្យច្បាស់ដូចនេះគឺ……

| | | |
|---|---|---|
| ត្រូវធ្វើបុណ្យខ្មើត | ម៉ែឪហូបកើត | កំពុងស្រេកឃ្លាន |
| ម៉ែឪនៅរស់ | កូនត្រូវធ្វើទាន | បំបាត់ក្តីឃ្លាន |
| | ហៅធ្វើបុណ្យខ្មើត ។ | |
| ហៅបុណ្យខែភ្លឺ | កុំចាំគាត់ឈឺ | បរិភោគលែងកើត |
| ជូនគាត់កាលជា | ហៅថាបុណ្យខ្មើត | គាត់បរិភោគកើត |
| | បានជាងរនោច ។ | |
| លុះបាត់ជីវិត | បុណ្យខែងងឹត | ដូចថ្ងៃ១០រោច |
| កូចចៅទាំងឡាយ | យកបាយឱ្យខ្មោច | ម៉ែឥតប្រយោជន៍ |
| | ខ្មោចណាចេះស៊ី ។ | |
| ម្យ៉ាងទៀតធ្វើបុណ្យ | ច្រើនតែចោលគុណ | គ្មានគិតរិះរេ |
| បោលទៅតែវត្ត | ម្តាយអត់ទទេ | ព្រោះជឿតាមគេ |
| | រកបុណ្យខាងក្រៅ ។ | |
| ដើមបុណ្យលើផ្ទះ | ខ្លួនកើតទាន់ព្រះ | កន្ទ្រោងគង់នៅ |
| បានត្រីត្រកាល | ទុកក្បាលឱ្យឪ | កណ្តាលនាំទៅ |
| | យកបុណ្យឯវត្ត ។ | |

នេះហៅបុណ្យខុស ទាំងស្រីទាំងប្រុស ខ្ញុំប្រាប់កុំខឹង
ម៉ែឪនៅរស់ ចូរអស់លោកប្រឹង ធ្វេញគាត់នៅរឹង
បានឆ្ងាញ់ពិសា ។

ខ្លះជឿបុណ្យខ្លាំង យួរម្ហូបទាំងឆ្នាំង យកទៅវត្តវ៉ា
ម៉ែឪអត់ឃ្លាន ចង់បានណាស់ណា ភ្លួយសួរកូនថា
មានសល់ឬទេ? ។

ព្រឹកឡើងឃ្លានបាយ ញ័រពោះញើសខ្វាយ ឃើញសម្លគេ
កូនឆ្លើយរឹងថ្កាន មិនបានសល់ទេ ខ្ញុំស្ល គ្រាន់តែ
ទៅវត្តទេឪ ។

ឪពុកសួរថា បើជួសកាលណា ចែកឪខ្លះទៅ
កូនខ្លះឆ្លើយប្រាប់ ថាបាបណាស់ឪ គេថាមិនត្រូវ
ឪស៊ីមុនលោក ។

ម៉ែឪចាស់ៗ ព្រឹកឡើងឃ្លានណាស់ គួរឱ្យវិយោគ
ឪទារពិសា កូនថាមុនលោក ពុំបានបរិភោគ
គេឱ្យបាបផង ។

នេះបុណ្យផ្កាប់មុខ ឬបុណ្យចោលស្រុក ព្រោះដើរផ្លូវឆ្គង
បុណ្យមិនត្រកាល វិសាលឡើយហោង ព្រោះដើរកន្លង
ឱ្យម៉ែឪអត់ ។

ពួកជនឈ្លានពាន មិនចេះធ្វើទាន ច្រើនធ្វើទានក្បត់
សទ្ធាមិនជ្រៅ ជ្រុលទៅតែវត្ត ឱ្យព្រះដើមអត់
ស្រែកឃ្លានពេកក្រៃ ។

ព្រះមហាថេរៈជាទីគោរព ញាតិញោមពុទ្ធបរិស័ទ ភ្ញៀវកិត្តយស និងក្រុមគ្រួសារសព ទាំងឡាយ ពេលនេះនៅសល់តែប៉ុន្មាននាទីទៀតប៉ុណ្ណោះ រូបរាងកាយរបស់ញោម អ្នកស្រីមហាឧបាសិកា**ហាន់ លី** នឹងរលត់ពីភ្នែករបស់យើងទាំងឡាយហើយ អ្វីដែលបន្សល់ទុកឱ្យយើងចងចាំជិតជាប់ក្នុងបេះដូងនិងជិតជាប់ក្នុងនេត្រានោះគឺបណ្តាំដែលធ្លាប់បានផ្តាំអោយកូនៗស្រលាញ់គ្នា និងថែរក្សាគ្នាទៅវិញទៅមក។ ជាពិសេសគឺសុំឱ្យកូនៗចៅៗទាំងអស់តាំងខ្លួនឱ្យស្ថិតក្នុងតែអំពើល្អ។ សូមឱ្យកូនចៅ

ទាំងអស់ ស្រង់យកពាក្យពេចន៍ដ៏មានតំលៃនោះ ទុកឱ្យជាប់ក្នុងក្រអៅបេះដូង និងផ្តិតឱ្យជាប់ក្នុងដួងនេត្រាជារៀងដរាបតទៅ ។

សូមអ្នកស្រីមហាឧបាសិកា កុំខ្វល់ខ្វាយ, បារម្ភ និងជាប់ជំពាក់ចំពោះកូនៗ ចៅៗ មាសប្រាក់ ឬញាតិសន្តានអី។ សូមអោយមហាឧបាសិកាធ្វើដំណើរតាមកុសលផលបុណ្យដែលជាស្ពានដែលបានកសាងហើយ ឆ្ពោះទៅរកទេវស្ថានវិមានសុខសម្រានចិត្តចុះ។ កូនចៅញាតិមិត្ត និងយើងខ្ញុំ ទាំងឡាយ នឹងខិតខំសន្សំបុណ្យកុសលផ្សព្វផ្សាយដល់លោកអ្នកដ៏មានគុណជារៀងរហូត ។

ដោយអំណាចនៃគុណបុណ្យព្រះរតនត្រ័យ បុណ្យកុសលដែលលោកយាយបានសន្សំហើយ និងបុណ្យកុសលដែលយើងខ្ញុំទាំងឡាយបានបានសន្សំទុកទាំងប៉ុន្មាន សូមឧទ្ទិសនិងបួងសួងអោយព្រះវិញ្ញាណក្ខន្ធដ៏បរិសុទ្ធិរបស់អ្នកស្រីមហាឧបាសិកា បានទៅសោយសុខគតិភពក្នុងសួគ៌វិមានរហូតបានសម្រេចនូវព្រះនិព្វានជាទីអវសាន្តនៃកងទុក្ខទាំងពួង កុំបីឃ្លៀងឃ្លាតឡើយ ។

មហាឧបាសិកា**ហាន់ លី** មានគុណធំ ជាម្ចាស់ទ្រទំនុកកូនចៅរាល់គ្នា
កាលលោករស់នៅចិញ្ចឹមរក្សា កូនគ្រប់អាត្មាសុខសាន្តធាត់ធំ ។
មហាឧបាសិកា មានព្រហ្មវិហារធម៌ មេត្តាបវរឱ្យបានសុខជុម
ករុណាបីបាច់កូនចៅតូចធំ មុទិតាឧបត្ថម្ភឧបេក្ខាចិត្ត ។
ថ្ងៃនេះកូនចៅសូមបង្គំវន្ទា ដល់គុណករុណាអ្នកម្ចាស់ជីវិត
សូមខមាទោសតូចធំឆ្ងាយជិត សូមគុណធម៌ពិតប្រោសប្រាណប្រណី។
យើងសូមបួងសួងដល់អស់ទេវតា គុណបុណ្យអស្ចារ្យព្រះពុទ្ធម្ចាស់ថ្លៃ
គុណបុណ្យមេត្តាសច្ចៈខន្តី តេជៈបារមីសូមនាំលោកយាយមហាឧបាសិកា
ទៅរកបរមសុខអើយ ។

ដោយសេចក្តីស្រលាញ់និងគោរពដ៏ខ្ពង់ខ្ពស់ពីស្វាមី កូនៗ ចៅៗ និង ញាតិមិត្ត ពុទ្ធបរិស័ទភៀវកិត្តយស ទាំងអស់ ។

សូមអរព្រះគុណ និង សូមអរគុណ